## អេម៉ានូអែល

សំលេងពីព្រះសហគមន៍កាតូលិក

*FM: 91 Mhz ខេត្តបាត់ដំបង*

*៧:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍*

*FM: 88 Mhz ខេត្តកំពង់ធំ*

*១២:៣០- ១:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍*

*FM: 102.5 Mhz ខេត្តសៀមរាប*

*១០:០០-១១:០០ នាទី រៀងរាល់ថ្ងៃសៅរ៍*

## ការិយាល័យផ្សព្វផ្សាយព័ត៌មាន ព្រះសហគមន៍ កាតូលិក រតនះ

- *បំលែងឯកសារពី VHS ទៅ DVD ទៅ VCD*
- *បំលែងចំរៀងពី កាសែតចម្រៀង ទៅ CD*
- *បង្កើតឯកសារវីឌីអូ សំរាប់ លោកឪពុក បងស្រី បងប្រុស។*

*ទំនាក់ទំនង ០៩២ ៦០៩ ៨៤៨*

## ព័ត៌មានប្រចាំខែ ភូមិភាគ បាត់ដំបង

- ថ្ងៃទី១១ កញ្ញា: គ្រូចុះទៅបំប៉នសិស្សនៅតាមសាលារដ្ឋ នៅព្រះសហគមន៍ស្វាយស៊ីសុផុន
- ថ្ងៃទី០៧ កញ្ញា: នៅព្រះសហគមន៍ កាតូលិកបាត់ដំបង មានការប្រជុំអំពី ព្រះជាម្ចាស់បានត្រាស់ហៅយើងអោយបំរើព្រះសហគមន៍។ ការប្រជុំនេះដឹកនាំដោយបងប្រុស ម៉ូង រស់។
- បងប្រុស ប្លាស (Br. Blas) បានត្រលប់ទៅប្រទេសហ្វីលីពីនវិញ កាលពីថ្ងៃទី១០ ខែកញ្ញា កន្លងទៅនេះ។ បងប្រុសបានធ្វើការជាមួយបុគ្គលិកនៅព្រះសហគមន៍ កាតូលិកបាត់ដំបង ជាច្រើន ដូចជាបង្រៀនភាពជាអ្នកណែនាំ បង្រៀនភាសា ធ្វើការជាមួយក្រុមសន្តវ៉ាំងសង់ដឺប៉ូល(SSVP) និងសម្របសម្រួលក្នុងផ្នែកអាហារូបករណ៍សិស្សក្រីក្រ។

## ល្បែងកំសាន្ត

សូមសង្កេត មើលមាន ចំនុច ៨ ដែលខុសគ្នា





Apostolic Prefecture of Battambang Monthly News. For Internal Circulation

# រតនះ
RATTANAK

មហាគ្រួសារព្រះសហគមន៍ កាតូលិក

Our Family

ព័ត៌មានព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ប្រចាំខែ កញ្ញា ឆ្នាំ ២០១២ លេខ ៤៣

## អង្គសន្និបាត "ជំនឿជាព្រះអំណោយទានរបស់ព្រះជាម្ចាស់"




ទំព័រ ៣

### មាតិកា


- គ្រូពេទ្យ និងនិស្សិតស្ម័គ្រចិត្ត សាំហ្គាពួរ មកពិនិត្យសុខភាពផ្នែកភ្នែក ទំព័រ ២
- សិក្ខាសាលា និងវគ្គបំប៉នដល់គ្រូមត្តេយ្យ ទំព័រ ៦
- ទិវាសន្តិភាពពិភពលោក ២១ កញ្ញា ទំព័រ ៤-៥

# គ្រូពេទ្យ និងនិស្សិតស្ម័គ្រចិត្ត សាំហ្គាពួរ មកពិនិត្យសុខភាពផ្នែកភ្នែក



Photo: Moy Samet

ដោយៈមុយ សាម៉េត

**នៅគ្រប់សរីរាង្គកាយរបស់មនុស្ស តែងតែមានសារៈសំខាន់ទាំងអស់ និងមានគុណប្រយោជន៍ដូចៗគ្នា ប៉ុន្តែយ៉ាងណាមិញ ភ្នែកក៏ជាផ្នែកមួយដ៏សំខាន់នៃសរីរាង្គកាយរបស់មនុស្ស ពីព្រោះភ្នែកអាចផ្តល់ផលប្រយោជន៍ ដូចជាមើលអក្សរ និងធ្វើអ្វីផ្សេងៗទៀត ដែលអាចធ្វើបាន។**

កាលពីពេលថ្មីៗនេះ នៅព្រះសហគមន៍ ភូមិភាគបាត់ដំបង មានក្រុមគ្រូពេទ្យ និងនិស្សិតស្ម័គ្រចិត្ត ខាងសុខភាពផ្នែកភ្នែក ដែលមកពីប្រទេសសាំហ្គាពួរ ដែលមានឈ្មោះហៅកាត់ថា វ៉ាយ ស៊ី អិម (YCM)បានពិនិត្យភ្នែក និងកាត់វ៉ែនតាដោយឥតគិតថ្លៃចាប់ពីថ្ងៃទី ២២-២៧ ខែកញ្ញា ឆ្នាំ២០១២។ ពួកគាត់ដែលអញ្ជើញមកនេះ មានចំនួន ២៨នាក់ និងចែកចេញជាបីក្រុម នឹងបីកន្លែងខុសៗគ្នាដូចជា ចុះតាមភូមិ មណ្ឌលដុនបូស្កូ និងតាមព្រះសហគមន៍។ គោលបំណងបី នៃការចុះជួយពិនិត្យភ្នែក និងកាត់វ៉ែនតា ទីមួយនោះគឺ ដើម្បីជួយដល់ជនក្រីក្រ ដែលគ្មានលទ្ធិភាពក្នុងការពិនិត្យភ្នែក និងកាត់វ៉ែនតា និងទីពីរគឺ ដើម្បីមើលនូវស្ថានភាព នៃជីវភាពក្នុងការរស់នៅរបស់បងប្អូនខ្មែរយើង ដែលមានភាពខ្វះខាត និងទីបីការប្រមូលវិភាគទាន ដែលបានពីអ្នកមកពិនិត្យភ្នែក ក្នុងការយកទៅជួយដល់ជនក្រីក្រ។ ក្នុងនោះក្រុមគ្រូពេទ្យ និងនិស្សិតស្ម័គ្រចិត្តបានចុះទៅជួយពិនិត្យភ្នែកក្នុងព្រះសហគមន៍ ភូមិភាគបាត់ដំបង និងស្រុកមួយចំនួនដូចជាព្រះសហគមន៍ កាតូលិកបាត់ដំបង ប៉ៃលិន តាហែន ពោធិ៍សាត់ កំពង់ឆ្នាំង ចំណោមស្ទឹង និគម ភូមិស្ពាន និងស្រុកឯកភ្នំ។ ការពិនិត្យភ្នែក និងកាត់វ៉ែនតា នៅក្នុងភូមិភាគបាត់ដំបងយើងនេះមានបងប្អូន ដែលមកពិនិត្យប្រហែលជាប្រមាណ ១០០០នាក់។ ហើយការពិនិត្យនេះ ក៏មានការបែងចែងជាបួនផ្នែក ក្នុងនោះផ្នែកទីមួយ គឺជាការសម្ភាសន៍ទៅលើសុខភាព និងវាស់ឈាមរបស់អ្នកមកពិនិត្យ និងផ្នែកទីពីរ គឺការធ្វើតេស្តភ្នែកដោយមើលអក្សរ ដែលមានចំងាយឆ្ងាយ និងផ្នែកទីបី គឺការពិនិត្យមើលដីក្រែភ្នែក និងផ្នែកទីបួន គឺការផ្តល់វ៉ែនតាដល់អ្នកមកពិនិត្យ ដែលតម្រូវឲ្យពាក់បន្ទាប់ពីបានធ្វើតេស្តរួច។ ស្របពេលនោះដែរលោកបូជាចារ្យ ម៉ានុច ដែលជាអ្នកមើលការខុសត្រូវ នៅមណ្ឌលសុខភាពប្រចាំព្រះសហគមន៍ កាតូលិកបាត់ដំបង ក៏មានប្រសាសន៍ផងដែរថា "សម្រាប់ការព្យាបាល និងពិនិត្យនេះគឺយើងមិនគិតថ្លៃអ្វីទាំងអស់នោះទេ ក៏ប៉ុន្តែពួកយើងមានវិភាគទានពីបងប្អូន ដែលមកពិនិត្យនៅទីនេះ ហើយវិភាគទានទាំងអស់នោះគឺយើងយកទៅជួយដល់ជនក្រីក្រនៅក្នុងភូមិស្រុកនៃប្រទេសកម្ពុជាយើង"។ លោកពូ កៅ ស្ងួម អាយុ៥៧ឆ្នាំ មកពីភូមិវត្តរំដួលក៏មានចំណាប់អារម្មណ៍ និងមានប្រសាសន៍ថា "ខ្ញុំមានអារម្មណ៍សប្បាយចិត្ត និងអរគុណជាខ្លាំងចំពោះក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ខាងសុខភាពភ្នែក ដែលបានចុះជួយពិនិត្យភ្នែកដោយមិនគិតជាថវិកា នេះជាការបង្ហាញឲ្យឃើញនូវចិត្តសប្បុរសធម៌ របស់ពួកគាត់ ដែលមកជួយពួកយើងនៅទីនេះ"។ លោកពូបានបន្តទៀតថា "តាមបំណងនិងចិត្តរបស់ខ្ញុំ ខ្ញុំចង់ឲ្យពួកគាត់មកច្រើនដង យ៉ាងហោចក្នុងមួយឆ្នាំបីដង"។



# សន្តី ថេរេសា នៅក្រុង លីស៊ីយឺ



**ក្នុងរតនៈលេខមុន យើងបានស្គាល់ សន្តី ថេរេសា នៅក្រុង លីស៊ីយឺ រីឯលេខនេះគឺ យើងបន្តអាននូវប្រវត្តិ របស់សន្តី ថេរេសា បន្តទៀត។ តើសេចក្តីត្រាស់ហៅរបស់ព្រះជាម្ចាស់ បានធ្វើឲ្យ ថេរេសា មានចិត្តយ៉ាងដូចម្តេច?តើ ថេរេសា បានបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះអង្គ ដោយយកអ្វីមកបញ្ជាក់? ដូចនេះ សូមអានក្នុងអត្ថបទខាងក្រោម នេះទាំងអស់គ្នា។**

នាងខ្ញុំបានយល់ថា៖បើសិនព្រះសហគមន៍ជាព្រះកាយ ហើយមានសរីរាង្គផ្សេងៗ ព្រះសហគមន៍ត្រូវតែមានបេះដូង ដែលសំខាន់ជាងគេ ហើយបេះដូងនេះធ្វើឲ្យកក់ក្តៅដោយសេចក្តីស្រលាញ់។ នាងខ្ញុំក៏យល់ថា "មានតែបេះដូង ដែលពរពេញដោយសេចក្តីស្រឡាញ់ប៉ុណ្ណោះ ទើបអាចផ្តល់កម្លាំងទៅគ្រប់សរីរាង្គ នៃព្រះសហគមន៍បាន។ ប្រសិនបើអស់សេចក្តីស្រឡាញ់គ្រីស្តទូត នឹងឈប់ប្រកាសដំណឹងល្អ និងមរណៈសាក្សី នឹងមិនព្រមបង្ហូរឈាមទេ"។ នាងខ្ញុំយល់ថា សេចក្តីស្រឡាញ់សរុបគ្រប់ការត្រាស់ហៅ របស់ព្រះជាម្ចាស់។ នៅពេលនោះនាងខ្ញុំបានបន្លឺសំលេងឡើងថា៖ ឱព្រះយេស៊ូ ជាទីស្រឡាញ់របស់នាងខ្ញុំ នាងខ្ញុំបានស្វែងយល់ឃើញ ការត្រាស់ហៅរបស់នាងខ្ញុំហើយ!ការត្រាស់ហៅរបស់នាងខ្ញុំ គឺសេចក្តីស្រឡាញ់!"។ ថេរេសានិយាយថែមទៀតថា៖ "ព្រះយេស៊ូអើយ!នាងខ្ញុំដឹងហើយថា គ្មានអ្វីក្រៅពីសេចក្តីស្រឡាញ់ ដើម្បីសងគុណនៃសេចក្តីស្រឡាញ់ ១២ របស់ព្រះជាអង្គម្ចាស់ ហេតុនេះនាងខ្ញុំស្វែងរកព្រមទាំងរកឃើញនូវមធ្យោបាយមួយ ដើម្បីធ្វើឲ្យបានខ្ញុំបានធូរចិត្ត គឺនាងខ្ញុំសម្រេចនឹងស្រឡាញ់ព្រះអង្គ"។ នៅពេលដែលជម្ងឺធ្វើអោយ ថេរេសា ខ្សោយណាស់ នាងបានបញ្ជាក់អំពីរបៀប ដែលនាងស្រលាញ់ព្រះអង្គ៖ "ឱ!ព្រះអង្គដ៏ជាទីស្រឡាញ់របស់នាងខ្ញុំ នាងខ្ញុំគ្មានមធ្យោបាយសំដែងសេចក្តីស្រឡាញ់របស់នាងខ្ញុំ ក្រៅពីបាច់ផ្កា ថ្វាយព្រះអង្គប៉ុណ្ណោះ។ ផ្ការបស់នាងខ្ញុំ គឺគ្រប់អំពើដែលនាងខ្ញុំប្រព្រឹត្តដោយសេចក្តីស្រឡាញ់ និងគ្រប់កិច្ចការដ៏តូចតាចរបស់នាងខ្ញុំ ពាក្យទាំងអស់ដែលខ្ញុំនិយាយ ព្រមទាំងសេចក្តីដ៏តូចតាចនៃជីវិតរបស់នាងខ្ញុំទាំងអស់"។ ថេរេសាយល់ថាផ្លូវដ៏តូចរបស់នាង ជាផ្លូវដែលគ្រីស្តបរិស័ទផងទាំងពួងអាចដើរបាន។ ជាហេតុនាងឆ្លើយតប ទៅនឹងបងស្រីម៉ារីថា៖ ហេតុដូចម្តេចបានជា បងស្រីសួរនាងខ្ញុំថា តើបងអាចស្រឡាញ់ព្រះជាម្ចាស់ដ៏សប្បុរស ដូចនាងខ្ញុំបានដែររឺទេ? ប្រសិនបើបងបានយល់សេចក្តី..........(តលេខក្រោយ)

# សិក្ខាសាលា និងវគ្គបំប៉នដល់គ្រូមត្តេយ្យ

ដោយៈ មុយ សាម៉េត

**ជារៀងរាល់ឆ្នាំ មុនបើកបង្រៀនសម្រាប់ថ្នាក់មត្តេយ្យ គ្រប់ព្រះសហគមន៍ដែលស្ថិតនៅក្នុងភូមិភាគបាត់ដំបង តែងតែមកចូលរួមសិក្ខាសាលា និងបំប៉នក្នុងផ្នែកមួយនៃការអប់រំខាងកុមារ ដើម្បីងាយស្រួលក្នុងការបង្រៀន និងមានវិធីសាស្ត្រជាច្រើនថ្មីៗក្នុងការបង្ហាញដល់ពួកគេ។**



Photo: Moy Samet

កាលពីថ្ងៃទី១៨–២០ ខែកញ្ញា ឆ្នាំ ២០១២ មានសិក្ខាសាលាសម្រាប់គ្រូមត្តេយ្យ ដែលរៀបចំឡើងនៅក្នុងព្រះសហគមន៍ កាតូលិកបាត់ដំបង។ សិក្ខាសាលានេះធ្វើឡើងជារៀងរាល់ឆ្នាំ មុនថ្ងៃការបើកបង្រៀនថ្នាក់មត្តេយ្យ ហើយក៏មានគោលបំណង ដើម្បីបណ្តុះបណ្តាលសម្រាប់គ្រូមត្តេយ្យ ឲ្យមានជំនាញខាងបង្រៀនថ្នាក់មត្តេយ្យ និងការផ្តល់នូវអ្វី ដែលប្លែកដូចជា ល្បែងកំសាន្ត សិល្បៈគំនូរ និងរបៀបបង្រៀនឲ្យក្មេងឆាប់ចេះ និងឆាប់យល់។ ក្នុងនោះក៏មានលោកគ្រូ អ្នកគ្រូ ដែលជាសិក្ខាកាមចូលរួម ៥៦នាក់ ដែលមកពីព្រះសហគមន៍ដូចជា ព្រះសហគមន៍កំពង់ធំ កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត តាហែន ចំណោម ប៉ៃលិន និងព្រះសហគមន៍ កាតូលិកបាត់ដំបង។ ក្នុងនោះមានគ្រូមត្តេយ្យរបស់ក្រសួងអប់រំ ខាងរដ្ឋាភិបាល ក៏បានចូលរួមក្នុងសិក្ខាសាលានេះផងដែរ។ ក្នុងរយៈពេលបីថ្ងៃនៃសិក្ខាសាលា ក៏មានការចូលរួមសម្របសម្រួលពីសំណាក់បងស្រី ៥នាក់ ដែលជាអ្នកជួយបង្រៀននៅក្នុងសិក្ខាសាលា អំពីរបៀបខុសៗគ្នាដូចជា ចម្រៀង ល្បែងកំសាន្ត ល្បងប្រាជ្ញា និងការបង្រៀនកូនក្មេង។ ស្របពេលនោះដែរ នៅថ្ងៃចុងក្រោយនៃសិក្ខាសាលា ដែលជាថ្ងៃបិទវគ្គ ក៏មានការចូលរួមពីសំណាក់លោកអភិបាល គីគេ និងលោកបូជាចារ្យ បីអង្គ គឺលោក ឪពុកតូតេ លោកឪពុក ពេកជ្រូ និងលោកឪពុក ម៉ានុច ដែលបានផ្តល់កិត្តិយស ក្នុងការចែកនូវសញ្ញាប័ត្រជូនទៅ ដល់សិក្ខាកាម និងធ្វើការសំណេះសំណាល ជាមួយសិក្ខាកាម ដែលបានចូលរួម។ ក្នុងនោះដែរ លោកអភិបាល គីគេ ក៏មានប្រសាសន៍ថា "ខ្ញុំសូមនិយាយអំពីសាលាមត្តេយ្យ ដែលពីមុនសម្រាប់ភូមិភាគយើងពុំសូវមានសាលាមត្តេយ្យនោះទេ ពីព្រោះដោយសារតែមានលោកគ្រូ អ្នកគ្រូតិច ប៉ុន្តែបែជាមានកូនក្មេងច្រើន និងពុំសូវមានអ្នកណែនាំដូចជាបងស្រីដូច្នេះវាធ្វើឲ្យយើងពិបាក ដោយសារយើងត្រូវការលោកគ្រូ អ្នកគ្រូ ច្រើន ដើម្បីបង្រៀនពួកគេ និងមើលថែពួកគេឲ្យបានល្អ"។ លោកអភិបាលបានបន្តទៀតថា "នៅក្នុងថ្ងៃនេះ ខ្ញុំសប្បាយចិត្តណាស់ ដោយបានឃើញលោកគ្រូ អ្នកគ្រូ ជាច្រើន ដែលបានចូលរួម និងមានបងស្រីក្នុងការជួយណែនាំពួកគាត់ នូវចំណេះដឹងថ្មីៗ។ ដូច្នេះម៉្យាងវិញទៀត វាក៏ជាតម្រូវការរបស់ភូមិភាគយើង ក្នុងការចូលរួមអភិវឌ្ឍន៍ធនធានមនុស្ស ឲ្យមានចំណេះដឹងតាមរយៈលោកគ្រូ អ្នកគ្រូ ជាពិសេសឲ្យពួកគេបានទទួលនូវអំណរសប្បាយ ពីព្រះជាម្ចាស់តាមរយៈលោកគ្រូ អ្នកគ្រូ ផងដែរ"។ ស្របពេលនោះដែរអ្នកគ្រូ ជា ស្រីញ៉ាវ អាយុ២២ឆ្នាំ មកពីព្រះសហគមន៍ ប៉ោយប៉ែត ក៏បានមានប្រសាសន៍ផងដែរថា "នេះជាលើកទីពីររបស់នាងខ្ញុំ ដែលបានចូលរួមក្នុងសិក្ខាសាលានេះ ហើយសិក្ខាសាលានេះ ក៏បានផ្តល់ចំណេះដឹងជាច្រើន ដូចជារបៀបនៃការបង្រៀនសិស្ស ការរៀបចំមេរៀន ហើយនិងសិល្បៈ"។ អ្នកគ្រូបាន បន្តទៀតថា "តាមបំណងចិត្ត របស់ខ្ញុំ ខ្ញុំចង់អោយមានសិក្ខាសាលានេះ ច្រើនដងទៀត ហើយនិងមានរយៈពេលយូរ"។



# អង្គសន្និបាត "ជំនឿជាព្រះអំណោយទានរបស់ព្រះជាម្ចាស់"




Photo: An Rittyrath

ដោយៈ មុយ សាម៉េត

កាលពីថ្ងៃទី០៤–០៦ ខែកញ្ញា ឆ្នាំ ២០១២ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានរៀបចំអង្គសន្និបាតអ្នកអប់រំជំនឿ និងយុវជនក្នុងប្រធានបទ "ជំនឿជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ "។ គោលបំណងរបស់ព្រះសហគមន៍ ភូមិភាគបាត់ដំបង បានជ្រើសរើសយកប្រធានបទនេះគឺនៅខែតុលា ឆ្នាំ២០១២ ខាងមុខនេះព្រះសហគមន៍ កាតូលិកទូទាំងសកលលោកយកជំនឿ ដើម្បីអោយគ្រីស្តបរិស័ទរិះគិតពិចារណា អំពីជំនឿរបស់ខ្លួនជាគ្រីស្តបរិស័ទ។ ក្នុងនោះក៏មានអ្នកអប់រំជំនឿ និងយុវជនមកពីបួនតំបន់គឺតំបន់បាត់ដំបង តំបន់អង្គរ តំបន់ទន្លេ និងតំបន់កំពង់ធំ ដែលមានអ្នកចូលរួម ២០០នាក់។ សម្រាប់ប្រធានបទក្នុងការរិះគិតនៅក្នុងថ្ងៃនីមួយៗ មានភាពខុសគ្នាដូចជា ថ្ងៃទីមួយមានប្រធានបទថា "តើជំនឿមានប្រភពមកពីណា?" ថ្ងៃទីពីរ "តើជំនឿជម្រុញឲ្យយើងធ្វើអ្វី?" ហើយនិងថ្ងៃទីបី "តើធ្វើដូចម្តេចដើម្បីណែនាំបន្តជំនឿ?" ។ គ្រប់ប្រធានបទទាំងអស់ត្រូវបានយកមករិះគិត និងពិភាក្សាតាមក្រុមនីមួយៗ ហើយធ្វើការបកស្រាយរាល់ប្រធានបទ ដែលបានពិភាក្សា និងរិះគិត។ ក្នុងរយៈពេលបីថ្ងៃក្នុងការរិះគិត និងពិភាក្សាក៏មានការចូលរួមពីសំណាក់លោកបូជាចារ្យ បងប្រុស បងស្រី ផងដែរ។ ក្នុងនោះដែរលោកឪពុក ពេជ្រូ ក៏មានប្រសាសន៍បកស្រាយ រាល់ប្រធានបទទាំងបីថ្ងៃដែរថា "នៅក្នុងឆ្នាំនេះ យើងបានលើកយកប្រធានបទ នឹងជាពិសេសអត្ថបទព្រះគម្ពីរលោក យ៉ូហានជំពូក៤ ព្រះយេស៊ូបានជួបជាមួយនឹងស្ត្រីសាម៉ារី មកដងទឹកនៅអណ្តូងទឹក ដែលព្រះយេស៊ូបានឈប់សម្រាក។ ដូច្នេះយើងចង់ឲ្យបងប្អូនយល់ថា ទឹកជាប្រភពនៃជីវិតហើយគឺជាជំនឿ និងជាព្រះអំណោយទាន មួយដែលទទួលបានពីព្រះជាម្ចាស់។ បើសិនជាយើង មិនបានទទួលនូវព្រះអំណោយទាននេះ យើងមិនអាចប្រតិបត្តិតាមជំនឿនេះបានទេ ពីព្រោះមានតែព្រះជាម្ចាស់ទេ ដែលជួយណែនាំយើង ប្រៀបបានដូចជាទឹកជាប្រភពនៃជីវិត។ ដូច្នេះជំនឿជាប្រភព ដែលយើងទទួលពីព្រះជាម្ចាស់ ដើម្បីឲ្យយើងរស់នៅ និងប្រតិបត្តិនូវអ្វីៗ ដែលយើងជឿ"។ លោកឪពុកបានមានប្រសាសន៍បន្តទៀតថា "សម្រាប់ប្រធានបទធំ នៅថ្ងៃទីពីរ "តើជំនឿជម្រុញឲ្យយើងធ្វើអ្វីខ្លះ?" មានន័យថា ជំនឿជម្រុញយើងឲ្យធ្វើអំពើល្អ ហើយនៅពេល ដែលយើងជឿយើង និងមានកម្លាំងពីព្រះជាម្ចាស់ ដើម្បីឲ្យយើងប្រព្រឹត្តអ្វីៗ ដែរល្អចំពោះអ្នកដ៏ទៃ និងឲ្យយើងមានសេចក្តីស្រឡាញ់ និងមានធម៌មេត្តាករុណា ការលើកលែងទោស នឹងយកចិត្តទុកដាក់ស្តាប់អ្នកដ៏ទៃ។ ចំនែកឯថ្ងៃទីបី "តើធ្វើដូចម្តេចដើម្បីណែនាំជំនឿ?"មានន័យថា គឺចង់ឲ្យបងប្អូនជាគ្រីស្តបរិស័ទ ទទួលការអប់រំបន្ថែម ហើយស្វែងយល់កាន់តែច្រើនឡើងៗ អំពីជំនឿរបស់ខ្លួនជាគ្រីស្តបរិស័ទ ដែលដើរតាម នឹងស្តាប់ព្រះបន្ទូល របស់ព្រះជាម្ចាស់"។ ស្របពេលនោះដែរ អ្នកគ្រូ ផា សុខហេង អាយុ២៦ឆ្នាំ មកពីព្រះសហគមន៍ ព្រែកស្បូវ ដែលជាគ្រូអប់រំជំនឿ ក៏មានប្រសាសន៍ថា "ក្នុងរយៈពេលបីថ្ងៃនេះ នាងខ្ញុំបានទទួលបទពិសោធន៍យ៉ាងច្រើន ពីអង្គសន្និបាតដូចជា ការរក្សាជំនឿ របៀបនៃការអប់រំជំនឿ ពិសេសបានស្គាល់ នៃសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់"។ ហើយនេះក៏ជាលើកទីមួយផងដែរ សម្រាប់សន្និបាតយុវជន និងគ្រូអប់រំនឿ។ ចុងបញ្ចប់នៃអង្គសន្និបាតក៏មានកម្មវិធីផងដែរ។



Photo: An RittyRath

**កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានរៀបចំនូវកម្មវិធីខួបកំណើតដល់លោកបូជាចារ្យ តូតេត អាយុ ៤៩ឆ្នាំឈានចូលអាយុ ៥០ឆ្នាំ។ កម្មវិធីនេះមានការចូលរួមពីសំណាក់បុគ្គលិក របស់ព្រះសហ–គមន៍ កាតូលិកបាត់ដំបង យ៉ាងសប្បាយរីករាយ។**



Photo: Moy Samet

**កម្មវិធីខួបកំណើតរបស់បងស្រី ឡឺ ធី ប៊ី សេស៊ីល បានរៀបចំឡើងកាលពីល្ងាចថ្ងៃទី២៣ ខែកញ្ញ ឆ្នាំ២០១២ នៅមណ្ឌលមេត្តាករុណា។ កម្មវិធីនេះមានការចូលរួមពីសំណាក់លោកបូជាចារ្យ តូតេត លោកបូជាចារ្យ ម៉ានុច និងយុវជន កុមារា កុមារី ដែលស្នាក់នៅសិក្សានៅទីនោះ ព្រមទាំងក្រុមរបាំរបស់ព្រះសហគមន៍ កាតូលិកបាត់ដំបង យ៉ាងសប្បាយរីករាយ ដោយមានការរាំលេងកម្សាន្តទៀផង។**

# ទិវាសន្តិភាពពិភពលោក ២១ កញ្ញា

ដោយៈអាន ឬទ្ធិរដ្ឋ



Photo: An RittyRath

នៅក្នុងបរិវេនសួននាគសន្តិភាព ក្រុងបាត់ដំបង កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ បានប្រារព្ធទិវាសន្តិពិភពលោក ២១ កញ្ញា យ៉ាឱឡារឹក។ ទិវាសន្តិភាពពិភពលោកនេះធ្វើឡើង ក្នុងគោលបំណងបង្កើន និងពង្រឹងទំនាក់ទំនាក់ក្នុងចំណោមប្រទេសជិតខាងតាមរយៈ ពង្រីកបណ្តាញរបស់ខ្លួន ដោយការចាប់អារម្មណ៍ជាបុគ្គល និងស្ថាប័ននានា ហើយបង្កើតការយល់ដឹងនូវគំនិតសន្តិភាព ឆ្ពោះទៅរការដោះស្រាយទំនាស់ផ្សេងៗ និងជាពិសេសចង់បង្ហាញ ឲ្យសាសនាទាំងអស់នៅលើពិភពលោកមានសន្តិភាព ដោយបំបាត់នូវទំនាស់ផ្សេងៗរវាងសាសនា។ កម្មវិធីបានប្រារព្ធឡើងវេលាម៉ោង ៧និង៣០នាទីព្រឹក ដោយមានការចូលរួមពីសំណាក់លោក ឌី ថេហ្វយ៉ា តំណាងក្រុមការងារដើម្បីសន្តិភាព លោក ណិប តៅ តំណាងសាសនាកាតូលិក ព្រះតេជគុណ សុវិជ្ជា តំណាងសាសនាព្រះពុទ្ធ និងមានតំណាងសាស–នាឥស្លាម ក៏បានចូលរួមជាគណៈអធិបតីផងដែរ។ កម្មវិធីនេះធ្វើឡើងដោយមានការគាំទ្រពីសាសនានីមួយៗ ដើម្បីសន្តិភាព និងមានការសហការណ៍ជាមួយសមត្ថកិច្ច ក្រុងបាត់ដំបងផងដែរ។ ទិវាសន្តិភាពពិភពលោកនេះ បានប្រារព្ធក្នុងក្រុងបាត់ដំបង ជាលើកទី៤នៅក្នុងឆ្នាំនេះ។ ស្របពេលនោះ លោក ឌី ថេហ្វយ៉ា ក៏បានមានប្រសាសន៍ដែរថា "ក្រុមការងារដើម្បីសន្តិភាពយើងនេះ គឺបង្កើតឡើងដើម្បីឲ្យប្រទេស ដែលមានជំលោះទាំងអស់នៅលើពិភពលោក នឹងជាពិសេសប្រទេស កម្ពុជា ថៃ ឡាវ និងវៀតណាមបង្កើតនូវសន្តិភាពរវាងគ្នានឹងគ្នា ដើម្បីឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍ និងរីកចំរើនទៅថ្ងៃអនាគត"។ ស្របពេលនោះដែរ លោក ណិប តៅ ក៏មានប្រសាសន៍ ផងដែរថា "សូមឲ្យសាសនាទាំងអស់ណែនាំមនុស្ស ដោយស្វែងរកសន្តិភាព កុំណែនាំឲ្យមានគ្រាប់មីននៅក្នុងចិត្ត ពីព្រោះសន្តិភាពកើតចេញពីចិត្ត របស់បុគ្គលម្នាក់ៗ ហេតុនេះ បើបុគ្គលម្នាក់មាននូវគ្រាប់មីនក្នុងចិត្តនោះនឹងធ្វើឲ្យប្រទេសជាតិ និងសាសនា ទាំងអស់នឹងមានជំលោះ។

Photo: An Rittyrath




**ក្នុងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១២ ជារៀងរាល់ឆ្នាំ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង តែតែងប្រារព្ធពិធី ខួបកំណើតរបស់លោកភិបាល គីគេ ហ្វីការេដូ យ៉ាងសប្បាយរីករាយ។ ក្នុងថ្ងៃនោះដែលមានបុគ្គលិក ព្រមទាំងបងប្អូនគ្រីស្តបរិស័ទជាច្រើន បានចូលរួមយ៉ាងកុះករ ដើម្បីរីករាយក្នុងថ្ងៃខួបរបស់លោកអភិបាល។ ស្របពេលនោះដែរមានតំណាងបុគ្គលិក តាមកន្លែងនីមួយៗ បានជូននូវកាដូអនុស្សាវរីយ៍ ជាច្រើនដល់លោកអភិបាលផងដែរ។**

# កម្មវិធីបិទវគ្គសាលាមត្តេយ្យពន្លកថ្មី



Photo: Moy Samet

កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ បិទវគ្គសាលាមត្តេយ្យពន្លកថ្មីនៅព្រះសហគមន៍ កាតូលិកបាត់ដំបង។ កម្មវិធីបិទវគ្គនេះមានគោលបំណងចង់អោយ មាតាបិតាសិស្សបានឃើញកូនរបស់ខ្លួនបង្ហាញសមត្ថភាពដូចជា ការច្រៀង សំដែងកាយវិការ និងផ្តល់រង្វាន់ជូនដល់សិស្សពូកែ។ កម្មវិធីនេះក៏មានការចូលរួមពីសំណាក់លោកបូជាចារ្យ តូតេត បងស្រី អ្នកគ្រូ មាតាបិតានិងសិស្សានុសិស្ស ដែលសិស្សមត្តេយ្យប្រមាណ ៩០នាក់។ ស្របពេលនោះដែរ លោកបូជាចារ្យ តូតេត ក៏បានមានប្រសាសន៍ផងដែរថា "ក្នុងថ្ងៃនេះខ្ញុំសប្បាយចិត្តខ្លាំងណាស់ ដែលបានចូលរួមក្នុងកម្មវិធីបិទវគ្គរបស់សាលាមត្តេយ្យពន្លកថ្មី។ ក្នុងនោះខ្ញុំសូមអរគុណចំពោះបងស្រី និងអ្នកគ្រូ ដែលបានថែទាំនឹងផ្តល់ចំណេះដឹងដល់ពួកគេ ហើយនេះពិតជាពិសេសខ្លាំងណាស់សម្រាប់ខ្ញុំ នូវពេលបានឃើញការសំដែងរបស់ពួកគេ"។ បន្ទាប់ពីលោកបូជាចារ្យបានមានប្រសាសន៍រួចមក មានកម្មវិធីចែករង្វាន់ដល់សិស្សពូកែចំនួន១៥នាក់ ដែលមានកំរិតខុសៗគ្នាដូចជាកំរិតទាប កំរិតមធ្យម និងកំរិតខ្ពស់។ អ្នកគ្រូ មុំ ជាគ្រូបង្រៀននៅសាលាមត្តេយ្យពន្លកថ្មី ក៏បានប្រាប់រតនៈយើងដែរថា "តាមពិតទៅកម្មវិធីបិទវគ្គនេះ គឺយើងតែងតែធ្វើជារៀងរាល់ខែប្រាំពីរ ប៉ុន្តែដោយសារតែមានជំងឺម្យ៉ាង ដែលសាហាវធ្វើអោយយើងសម្រេចចិត្តផ្អាក និងលើកយកមកធ្វើក្នុងខែប្រាំបួនវិញ"។ ចុងបញ្ចប់នៃកម្មវិធីនេះ ក៏មានការសំដែងជាច្រើនពីកុមារា កុមារី ដែលជាសិស្សគ្រប់កំរិតក្នុងការសំដែងជូនដល់អ្នកចូលរួមបានទស្សនា នូវសមត្ថភាពរបស់ពួកគេដែលសិក្សារៀនសូត្រអស់រយៈពេលមួយឆ្នាំមក។ **ដោយៈមុយ សាម៉េត**